# ការចូលរួមរបស់ភាគីពាក់ព័ន្ធ

នីតិវិធីនៃការចូលរួមសម្រាប់LCAP និងការកែតម្រូវប្រចាំឆ្នាំ

**តើដោយរបៀបណា នៅពេលណា ជាមួយអ្នកណា ដែលក្រសួងអប់រំបានធ្វើការពិភាក្សា ដែលជាចំណែកមួយនៃនីតិវិធីក្នុងការរៀបចំគ្រោងសម្រាបLCAP ការពិនិត្យមើលប្រចាំឆ្នាំ និងការធ្វើវិភាគ?**

ក្រសួងអប់រំឡុងប៊ីច Long Beach Unified School District មានរចនាសម្ព័ន្ធរឹងមាំសម្រាប់ធ្វើទំនាក់ទំនងដែលមានប្រសិទ្ធិភាពជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេស ជាមួយគោលដៅយុទ្ធសាស្ត្រ។ LBUSD ក៏ជឿជាក់ដែរលើរចនាសម្ព័ន្ធប្រព័ន្ធ -ខ. អនុវត្តវិធានការសមភាពថិតថេរជាមួយសេចក្តីរំពឹងខ្ពស់សម្រាប់សាលានិងសិស្សទាំងអស់។

ជាមួយការពិភាក្សានឹងភាគីពាក់ព័ន្ធនិង LCAP , LBUSD បានស្ថាបនាបន្តពីគម្រោងទំនាក់ទំនងមានប្រសិទ្ធិភាពទាំងនេះ ដូច្នេះហើយ បង្កើនល្បឿននៃការដាក់បញ្ចូលអាទិភាពទាំង៨របស់រដ្ឋនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់សាលារៀន។ ស្របពេលជាមួយគ្នានេះដែរ គេបានរៀបចំឲ្យស្របគ្នាជាមួយផែនការយុទ្ធសាស្ត្រ កិច្ចសន្យាឡុងប៊ីច Long Beach College Promise និងកម្មវិធីផ្សេងៗទៀតរបស់សាលារៀន។

LBUSD បានប្រើយុទ្ធសាស្ត្រពិភាក្សាជាមួយភាគីពាក់ព័ន្ធដែលយកចិត្តទុកដាក់ទៅលើស្ថេរភាពរបស់ LCAP ។ គោលការណ៏សំខាន់ៗរបស់យុទ្ធសាស្ត្រនេះមាន:

1. **យកចិត្តទុកដាក់លើការបន្ថែមចំនួនភាគីពាក់ព័ន្ធដើម្បីឲ្យពួកគេជាម្ចាស់លើកិច្ចការ។** LBUSD យកចិត្តទុកដាក់លើភាពងាយស្រួលនៃការធ្វើទំនាក់ទំនងរបស់ខ្លួន តែងតែបំបែកប្រធានបទឲ្យទៅជាផ្នែកតូចៗងាយនឹងយល់ ហើយដែលលាតត្រដាងជាយុទ្ធសាស្ត្រតាមលំដាប់លំដោយពេញមួយឆ្នាំសិក្សា។

2. **រៀបចំឲ្យស្របគ្នានូវកម្មវិធីថ្មីៗផ្សេងៗឲ្យទៅជាសារមានខ្លឹមសារដើម្បីឲ្យភាគីពាក់ព័ន្ធយល់ឲ្យបានទូលំទូលាយ។** LBUSD ឲ្យតម្លៃលើការកែទម្រង់នូវកិច្ចការចាស់ ភ្ជាប់ឲ្យមានទំនាក់ទំនង ហើយពន្យល់ឲ្យយល់នូវកិច្ចការដែលស្មុគស្មាញ។

3. **ប្រើរចនាសម្ព័ន្ធទំនាក់ទំនងដែលមានរួចមកហើយដើម្បីឲ្យកម្មវិធីថ្មីៗក្លាយជាចំណែកធម្មតាមួយនៅក្នុងកិច្ចការបន្តបន្ទាប់របស់ភាគីពាក់ព័ន្ធ។** LBUSD ពឹងផ្អែកទៅលើការជួបប្រជុំដែលមានរាយខាងក្រោមនេះដើម្បីពង្រឹងដល់ការធ្វើទំនាក់ទំនងទៅវិញទៅមក ដែលជាប់រដឹក ហើយដែលមានប្រយោជន៏។

ដោយបានដាក់បញ្ចូលផ្ទៃរឿង LCAP នៅក្នុងរចនាសម្ព័ន្ធទំនាក់ទំនងជាយូរអង្វែង LBUSD បានធ្វើការបញ្ជាក់ថាការពិភាក្សាជាមួយភាគីពាក់ព័ន្ធនឹងមានភាពញឹកញាប់ ទាន់ពេលវេលា និងមានន័យ។ ការប្រជុំខាងក្រោមនេះ មាននូវប្រធានបទ LCAPក្នុងរបៀបវារៈ ឬប្រធានបទដែលទាក់ទងនឹង LCAP ។ ទៅតាមការសមរម្យ យោបល់នឹងត្រូវប្រមូលមកតាមរយៈការស្ទង់មតិ ក្រដាសសរសេរ ឬការពិភាក្សាគ្នាដោយបើកចំហរ (ក្រោយមកនឹងសរសេរជាកំណត់ហេតុប្រជុំ)។ ការប្រជុំមួយចំនួនក៏នឹងមានផ្សាយក្នុងទូរទស្សន៏លើលេខប៉ុស្តិរបស់ក្រសួងអប់រំនិងនៅគេហទំព័រ lbschools.net ។

| ក្រុម | ភាគីពាក់ព័ន្ធ | ភាពញឹកញាប់ |
|---|---|---|
| អភិបាលសាលា | **នាយកសាលានិងអនុនាយកសាលា**<br>ការប្រជុំប្រចាំខែរបស់ក្រសួងអប់រំជាមួយអភិបាលសាលា | ប្រចាំខែ |
| អភិបាលសាលា | **Association of Long Beach Educational Managers and Confidential Employees**<br>ការប្រជុំរបស់អគ្គនាយកសាលាជាមួយ ALBEM. | ប្រចាំខែ |
| គ្រូបង្រៀន / បុគ្គលិក | **ក្រុមប្រឹក្សាគ្រូបង្រៀន**<br>ការជួបប្រជុំជាមួយអ្នកតំណាងគ្រូបង្រៀន | ត្រីមាស |
| គ្រូបង្រៀន / បុគ្គលិក | **Coffee with Chris**<br>ការជួបប្រជុំជាមួយអគ្គនាយកសាលាសម្រាប់បុគ្គលិក | ត្រីមាសទី |
| គ្រូបង្រៀន / បុគ្គលិក | **សមាគមគ្រូបង្រៀននៅឡុងប៊ីច TALB**<br>ការជួបប្រជុំរវាងអគ្គនាយកសាលាជាមួយប្រធានសហជីពគ្រូបង្រៀន | ប្រចាំខែ |
| គ្រូបង្រៀន / បុគ្គលិក | **សមាគមអ្នកធ្វើការសាលារដ្ឋកាលីហ្វ័រនីញ៉ា CSEA**<br>កាប្រជុំរវាងអគ្គនាយកសាលានិង CSEA. | ប្រចាំខែ |
| មាតាបិតា | **ក្រុមប្រឹក្សាសហគមន៍ District Community Advisory Committee**<br>ការជួបប្រជុំជាមួយគ្រួសារនៃកម្មវិធី Title I, ក្រុមប្រឹក្សាសាលា<br>និងមាតាបិតាជាអ្នកដឹកនាំផ្សេងៗ | ប្រចាំខែ |
| មាតាបិតា | **ក្រុមប្រឹក្សាអ្នករៀនភាសាអង់គ្លេស DELAC**<br>ការជួបប្រជុំជាមួយគ្រួសារអ្នករៀនភាសាអង់គ្លេសនិងមាតាបិតាអ្នកដឹកនាំ | ប្រចាំខែ |
| មាតាបិតា | **Concerned African American Parents**<br>ការជួបប្រជុំជាមួយគ្រួសារស្បែកខ្មៅនិងមាតាបិតាជាអ្នកដឹកនាំ | ប្រចាំខែ |
| មាតាបិតា | **Superintendent Parents Forum**<br>ការជួបប្រជុំរវាងអគ្គនាយកសាលានិងអ្នកតំណាងមាតាបិតាពីសាលារៀន | ត្រីមាស |
| មាតាបិតា | **ការប្រជុំមាតាបិតានៃសិស្សសាលាសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ**<br>ស្រដៀងគ្នានឹងការប្រជុំមាតាបិតាជាមួយអគ្គនាយកសាលា ដែលយកចិត្តទុកដាក់លើកំរិតថ្នាក់ផ្សេងៗ | ត្រីមាស |
| សិស្ស | **ក្រុមប្រឹក្សាសិស្ស Superintendent’s Student Advisory Committee**<br>ការជួបប្រជុំរវាងអគ្គនាយកសាលាជាមួយអ្នកតំណាងសិស្សពីសាលាវិទ្យាល័យ. | ប្រចាំខែ |

| | | | |
|---|---|---|---|
| សហគមន៍ | **សិក្ខាសាលាក្រុមប្រឹក្សាភិបាលនៃការអប់រំ Board of Education Workshops**<br>ការប្រជុំជាសាធារណៈសម្រាប់បុគ្គលិកសាលាជាមួយក្រុមប្រឹក្សាការអប់រំ ដើម្បីពិភាក្សាអំពីកិច្ចការយុទ្ធសាស្ត្រផ្សេងៗ។ | ត្រីមាស |
| សហគមន៍ | **គណៈកម្មាធិការក្រុមប្រឹក្សា LCAP Advisory Committee**<br>ក្រុមប្រឹក្សាដែលមានសិស្ស៦០នាក់ បុគ្គលិក សមាជិកសហគម និងភាគីពាក់ព័ន្ធផ្សេងទៀតដែលធ្វើអនុសាសន៍លើបទបញ្ហាដល់ក្រុមប្រឹក្សាភិបាល | ត្រីមាស |
| សហគមន៍ | **ពិធីផ្សេងៗ ការជួបប្រជុំជាមួយដៃគូរ**<br>ឱកាសសម្រាប់ទទួលយោបល់ស្តីពីLCAP, ដែលមានរួមអង្គការ Ministerial Alliance; the Long Beach College Promise;. ។ល។ | ម្តងម្កាល |

**ឆមាសទីមួយ (ខែសីហា 2017 – ខែមករា 2018)**

នៅក្នុងឆមាសទីមួយនៃឆ្នាំសិក្សា 2017-18 LBUSD បានបញ្ជាក់ឡើងវិញនូវសាលារៈសំខាន់នៃការដាក់ប្រតិបត្តិនូវ LCAP ហើយរៀបចំគ្រឹះសម្រាប់យុទ្ធនាការផ្សព្វផ្សាយ។ យុទ្ធនាការនេះគឺដើម្បីជួយភាគីពាក់ព័ន្ធឲ្យមានការយល់ដឹងជ្រៅជ្រះថែមទៀតទៅលើ LCAP : គឺធនធានអ្វីមួយដែលផ្តល់ឲ្យផែនការ ការរៀបចំឲ្យស្របគ្នារវាងផែនការយុទ្ធសាស្ត្រនិងគោលដៅ LCAP ហើយនិងសមិទ្ធិកម្មសំខាន់ៗរបស់ LCAP ដែល LBUSD បានធ្វើសម្រេចមក។

ការខ្នះខ្នែងពីគ្រោះពិភាក្សាជាមួយភាគីពាក់ព័ន្ធត្រូវបានចែកទៅជាបីដំណាក់ (រយៈពេលនៅក្នុងខែសីហា-កញ្ញា ខែតុលានិងវិច្ឆិកា និងខែធ្នូទៅខែមករា)

1. LBUSD រៀបបំរុងអ្នកដឹកនាំក្រសួងអប់រំនិងសាលារៀនសម្រាប់ដាក់ប្រតិបត្តិឲ្យស្ថិតស្ថេរនូវ LCAP នៅក្នុងប្រព័ន្ធសាលារៀន។ សិក្ខាសាលាក្រុមប្រឹក្សាភិបាលនៅខែសីហាពិភាក្សាអំពីគោលដៅ LCAP ហើយនិងភាពស្របគ្នារវាងគោលដៅទៅនឹងផែនការយុទ្ធសាស្ត្រ តារាងទិន្នន័យក្រសួងអប់រំ ហើយនិងរបៀបដែលវាស៊ីគ្នាទៅនឹងតារាងពិន្ទុរបស់រដ្ឋ California Schools Dashboard; ហើយនិងសកម្មភាពរៀបបំរុងសិស្សឲ្យមានភាពរួចរាល់សម្រាប់សាកលវិទ្យាល័យនិងអាជីព ហើយនិងរបៀបដែលវាគាំទ្រដល់កិច្ចសន្យា Long Beach College Promise ។

2. សិក្ខាសាលាក្រុមប្រឹក្សាភិបាលនៅខែវិច្ឆិកាកាន់តែមានភាពជ្រៅជ្រះជាងសិក្ខាសាលនៅខែសីហាទៅទៀត។ នៅក្នុងប្រធានបទដែលមានចំណងជើងថា "បំបិទចន្លោះសមិទ្ធិកម្ម" អ្នកតំណាងមកពីសាលាបឋមសិក្សា អនុវិទ្យាល័យ K-8 និងសាលាវិទ្យាល័យ បានពណ៌នារបៀបផ្សេងៗដែលពួកគេស្វែងរកការគាំទ្រដល់សិស្សដែលមានលក្ខណៈពិសេស រួមទាំងសិស្សស្បែកខ្មៅ ហ៊ិសស្ប៉ានិក និងសិស្សរៀនភាសាអង់គ្លេសផងដែរ។ បទបង្ហាញអំពីតារាងលទ្ធផល California Schools Dashboard ក៏បានធ្វើឡើងដែរ។ ជាទីបញ្ចប់ ចំណុចពិសេសមួយនៃកម្មវិធី LCAP គឺគំរោងនៃភាពសុខដុម Harmony Project ត្រូវបានលើកយកមកពិភាក្សាយ៉ាងក្បោះក្បាយ។

3. យុទ្ធនាការផ្សព្វផ្សាយរបស់ LBUSD ចាប់ផ្តើមជាមួយការចែកចាយឯកសារ "It Takes a Village," ដែលជាឯកសារមួយសង្ខេបពីរបៀបជាច្រើនយ៉ាងដែលសាលារៀន មាតាបិតា និងដៃគូរសហគមន៍អាចធ្វើការរួមគ្នាដើម្បីជួយសិស្ស។ ដែលជាការដឹកនាំសម្រាប់ប្រើប្រាសកម្មវិធី LCAP (មានរួមទាំងកម្មវិធីសាលារៀន ធនធានគ្រួសារ និងធនធានសហគមន៍ដែលគាំទ្រ

ដល់សមិទ្ធិកម្មនៃការសិក្សា ឯកសារ “It Takes a Village” បម្រើជាចំណុចបង្គោលសម្រាប់ការពិគ្រោះពិភាក្សាជាមួយភាគីពាក់ព័ន្ធ។ ឧទាហរណ៏: នៅក្នុងការប្រជុំខែមករាសម្រាប់ការប្រជុំរវាងអគ្គនាយកសាលានិងមាតាបិតាហើយនិងគណៈកម្មាធិការក្រុមប្រឹក្សា LCAP អ្នកដឹកនាំក្រសួងអប់រំ បានចាត់ចែងសម្រួលការប្រជុំដោយអានឯកសារ “It Takes a Village” មុននឹងធ្វើលំហាត់រចនាសម្ព័ន្ធ ដែលភាគីពាក់ព័ន្ធបានដាក់ជាអាទិភាពនៅក្នុងអនុសាសន៏ LCAP ។

**ឆមាសទីពីរ (ខែកុម្ភៈ 2018 – ខែមិថុនា 2018)**

នៅក្នុងឆមាសទីពីរនៃឆ្នាំសិក្សា 2017-18 LBUSD បានធ្វើបន្តយុទ្ធនាការផ្សព្វផ្សាយ LCAP ហើយផ្តល់ការកែតម្រូវជាផ្លូវការនិងការខ្នះខ្នែងរៀបចំផែនការរបស់ក្រសួងអប់រំ។ សកម្មភាពទាំងនេះពន្យល់អំពីលទ្ធផលរបស់ក្រសួងអប់រំទៅលើគោលដៅផ្សេងៗរបស់ LCAP ហើយទាមទារយោបល់ពីភាគីពាក់ព័ន្ធដោយប្រការផ្សេងៗ។

ដូចគ្នានឹងឆមាសទីមួយដែរ ការខ្នះខ្នែងពិគ្រោះពិភាក្សាជាមួយភាគីពាក់ព័ន្ធត្រូវបានចែកទៅជាបីដំណាក់ (រយៈពេលនៅក្នុងកុម្ភៈ ខែមិនា-ខែមេសា និងខែឧសភាទៅខែមិថុនា)

1. LBUSD បានផ្សាយរបាយការណ៏សហគមន៏មួយឈុតដែលមានចំណងជើងថា “ការបន្លេចនូវផែនការគ្រប់គ្រងនិងទំនួលខុសត្រូវរបស់សាលា” “Local Control and Accountability Plan Highlights,” ដែលមានពណ៌នាអំពីដំណើរទៅមុខរបស់ក្រសួងអប់រំលើផ្នែក ឧត្តមភាពនៃការសិក្សា សេវាកម្មមូលដ្ឋាន និងការខ្នះខ្នែងជាក្រុមរវាង មាតាបិតា-សិស្ស-និងសាលា។ របាយការណ៏ទាំងនេះមាននូវសេចក្តីសង្ខេបគោលដៅរបស់ LCAP សេវាកម្មសំខាន់ៗ និងព័ត៏មានពីថវិការ។ វាមានភាពស៊ីគ្នាទៅនឹងការណែនាំរបស់ “It Takes a Village” ហើយនិងសេចក្តីសង្ខេបផែនការយុទ្ធសាស្រ្ត ហើយត្រូវបានចែកចាយជាក្រដាសនិងតាមរយៈអនឡាញ។

2. ការស្ទង់មតិក្នុងក្រសួងអប់រំមួយត្រូវបានប្រព្រឹត្តធ្វើឡើងជាភាសាអង់គ្លេស ស្ប៉ែនិស និងខ្មែរ តាមរយៈប្រព័ន្ធ SchoolMessenger និង SchoolLoop របស់ LBUSD ព្រមតាំងតាមរយៈគេហៈទំព័រ lbschools.net ផងដែរ។ សំណួរ បានផ្តោតទៅលើគោលដៅធំៗទាំង៧របស់ LCAP ហើយនិងការទាមទាយោបល់ដើម្បីកែធ្វើឲ្យប្រសើរឡើង។ លទ្ធផលត្រូវបានពិនិត្យមើលជាមួយគណៈកម្មាធិការភាគីពាក់ព័ន្ធហើយបានទទួលយកយោបល់និងអនុសាសន៏បន្ថែម។

3. LBUSD បានដាក់បញ្ចូលក្រដាសផ្តល់យោបល់ពីការស្ទង់មតិនិងការប្រជុំផ្សេងៗ ព្រមទាំងការតម្រូវឲ្យមានការពិភាក្សាជាមួយគណៈកម្មាធិការក្រុមប្រឹក្សា the District Community Advisory Committee និង District English Learner Advisory Committee ។ បន្ទាប់ពីសួរភាគីពាក់ព័ន្ធរកយោបល់ថែមទៀត បុគ្គលិកក្រសួងអប់រំដាក់បញ្ចូលលទ្ធផលសំខាន់ៗពី LCAP, ធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាក្រុមប្រឹក្សាភិបាលការអប់រំនៅខែមិនានិងនៅក្នុងពេលប្រជុំសាធារណៈ។

LBUSD បានផ្សាយចម្លើយជាលាយលក្ខណ៏អក្សររបស់អគ្គនាយកសាលាទៅដល់យោបល់របស់ភាគីពាក់ព័ន្ធ។ ភាគច្រើន ចម្លើយត្រូវបានធ្វើឡើងជាកំណត់ហេតុនៃការប្រជុំជាផ្លូវការសម្រាប់ក្រុមប្រឹក្សា District Community Advisory Committee និង District English Learner Advisory Committee ដែលសមាជិកបានទទួលការយល់ព្រម។ នៅករណីផ្សេងទៀត ចម្លើយជាសំបុត្រ បានផ្ញើទៅឲ្យភាគី ពាក់ពន្ធ័ផ្ទាល់។

## ការប៉ះពាល់លើ LCAP និងការកែតម្រូវប្រចាំឆ្នាំ

**តើការពិភាក្សាទាំងនេះមានឥទ្ធិពលទៅលើ LCAP នៅឆ្នាំក្រោយដោយរបៀបណា?**

ជាមួយយោបល់ពីភាគីពាក់ព័ន្ធនៅក្នុងការពិភាក្សា LCAP , LBUSD បានប្រតិបត្តិដូចតទៅ:

### ពង្រីកការផ្សព្វផ្សាយឲ្យបានច្រើនថែមទៀតក្នុងសហគម

យោងតាមយោបល់ពីភាគីពាក់ព័ន្ធ LBUSD បានចាត់វិធានការថែមទៀតដើម្បីបញ្ចូលរួមសហគមទាំងមូល។ ឯកសារ “It Takes a Village” ជាឧទាហរណ៏ បានចែងនូវសហការជាមួយប្រព័ន្ធបណ្ណាល័យ Long Beach Public Library ហើយពន្យល់អំពីរបៀបដែលធនធាននេះគាំទ្រដល់គោលដៅ LCAP ដោយរបៀបណា។ ថែមពីនោះទៀត វាមានផ្តល់ឲ្យសិស្សនិងគ្រួសារ ឲ្យអាចប្រើប្រាសកម្មវិធិសម្រាប់គាំទ្រដល់ការសិក្សា ដូចជាកម្មវិធី LearningExpress, Brainfuse ជាដើម ដោយប្រើប័ណ្ណសមាជិកបណ្ណាល័យ។

នៅនិទាឃរដូវ LBUSD ចូលរួមប្រជុំជាមួយអង្គការសហគមនិងភាគីពាក់ព័ន្ធផ្សេងៗទៀតដើម្បីចែកចាយព័ត៏មានពី LCAP, ស្វែងរកយោបល់ ហើយគិតសម្រេចមើលថាតើការខ្វះខ្នែងរួមគ្នាអាចប្រើប្រាសដោយរបៀបណាដើម្បីគាំទ្រដល់សិស្សក្នុងលក្ខណះពិសេស។ កិច្ចការនេះគឺស្ថាបនាបន្តពីការជួបប្រជុំជាមួយសហគមផ្សេងៗទៀតដែលបានប្រព្រឹត្តធ្វើទៅពេញមួយឆ្នាំ ចាប់ផ្តើមជាមួយការប្រជុំទាក់ទងនឹង LCAP ហើយនិងពិធីសន្និសិទ Californians for Justice និង the California Conference for Equality and Justice កាលពីខែកក្កដា July 2017 ។

### ការធ្វើឲ្យស្របគ្នាផែនការយុទ្ធសាស្រ្តនឹងគោលដៅ LCAP

ដោយសារតែគោលដៅ LCAP ត្រូវបានកែឡើងវិញកាលពីឆ្នាំមុន ភាគីពាក់ព័ន្ធបានឲ្យយោបល់ថា គោលដៅផែនការយុទ្ធសាស្រ្តរបស់ LBUSD គួរតែកែសម្រួលឡើងវិញតាមរបៀបដូចគ្នា។ ការធ្វើឲ្យស្របគ្នានេះនឹងជួយពង្រឹងដល់សញ្ញាណថាក្រសួងអប់រំកំពុងធ្វើការឆ្ពោះទៅគោលដៅរួមជាជាងដោយឡែកពីគ្នា។

| ផែនការយុទ្ធសាស្រ្ត | LCAP |
|---|---|
| បញ្ជាក់នូវភាពសមភាពសម្រាប់សិស្សទាំងអស់ | សិស្សនឹងទទួលសេវាកម្មមូលដ្ឋានដែលជាគ្រិះសម្រាប់ជោគជ័យដល់ការសិក្សា |
| ផ្តល់បរិយាកាសសិក្សា ដែលទទួលស្វាគម មានការគោរពគ្នា និងការសិក្សាដ៏ម៉ត់ចត់សម្រាប់រាល់សមាជិករបស់សហគម | សាលារៀននឹងជាកន្លែងមួយដែលមានសុវត្ថិភាព ទាក់ទាញចិត្ត បញ្ចូលរួមអ្នករាល់គ្នានិងមានការគាំទ្រដល់សិស្ស មាតាបិតា និងបុគ្គលិក |
| បណ្តុះបណ្តាលការលូតលាស់នៃការសិក្សាដល់សិស្សគ្រប់រូប | សិស្សនឹងរៀនឲ្យបានលូតលាស់តាមស្តង់ដារមុខវិជ្ជាស្នូលសាមញ្ញរបស់រដ្ឋ<br>សិស្សនឹងមានជោគជ័យលើពិជគណិតដើម្បីបញ្ជាក់ការរៀនឲ្យចប់ពីវិទ្យាល័យហើយពង្រីកឱកាសទៅរៀននៅសាកលវិទ្យាល័យនិងអាជីព<br>សិស្សនឹងរៀនថ្នាក់ពិបាកៗ រួមទាំងថ្នាក់កំរិតសាកលវិទ្យាល័យ Advanced Placement. |

| | |
|---|---|
| | សិស្សនឹងចូលរួមជាសកម្មនៅក្នុងរៀនសូត្រ |
| បង្កើតភាពរួចរាល់សម្រាប់សាកលវិទ្យាល័យនិងអាជីពសម្រាប់សិស្សគ្រប់គ្នា | សិស្សនឹងបង្ហាញភាពរួចរាល់សម្រាប់សាកលវិទ្យាល័យនិងអាជីព |
| គាំទ្រដល់ទំនាក់ទំនងដែលមានប្រសិទ្ធិភាពនៅទូទាំងក្រសួងអប់រំ | |

**អន្តរាគមនតម្រង់បន្ថែមទៀត**

យោងទៅតាមសេចក្តីចាំបាច់ជាគោលរបស់អ្នករៀនភាសាអង់គ្លេស LBUSD បានធ្វើការសង្កត់បញ្ជាក់ឡើងវិញលើអន្តរាគមន៏សម្រាប់អ្នករៀនភាសាអង់គ្លេស។ គណៈកម្មាធិការក្រុមប្រឹក្សារបស់ក្រសួងអប់រំដែលមាន District Community Advisory Committee, District English Learner Advisory Committee, និងក្រុមប្រឹក្សា LCAP Advisory Committee ហើយនិងការជួបប្រជុំជាមួយអគ្គនាយកសាលា បានទាមទារឲ្យមានការគាំទ្របន្ថែម ដូច្នេះអ្នកដឹកនាំពីក្រសួងអប់រំបានធ្វើការយ៉ាងជិតស្និតជាមួយសាលារៀនដើម្បីផ្តល់ការបង្ហាត់បង្រៀនបន្ថែមនិងសេវាកម្មគាំទ្រផ្សេងៗទៀតសម្រាប់សិស្សរៀនភាសាអង់គ្លេស។ ថែមពីនោះទៀត ការបិទចន្លោះសមិទ្ធិកម្មសម្រាប់សិស្សស្បែកខ្មៅ ជាពិសេសក្នុងមុខវិជ្ជាគណិតវិទ្យា គឺជាអាទិភាពខ្ពស់ជាងគេ ហើយ LBUSD បានពង្រីកការខ្នះខ្នែងនៅក្នុងចំណុចនេះ ដោយធ្វើឲ្យស្របគ្នានូវកិច្ចការរបស់ LCAP ជាមួយនឹង កម្មវិធីកែទម្រង់ការសិក្សារបស់សរដ្ឋ California Office to Reform Education (CORE) ។ ដូចដែលបានពណ៌នាក្បោះក្បាយនៅក្នុងផ្នែកមួយនៃឯកសារ “LCAP Highlights” យោបល់ផ្សេងៗពីភាគីពាក់ព័ន្ធបាននាំទៅដល់ការឲ្យមានថែមទៀតនូវកម្មវិធីបង្ហាត់បង្រៀនបន្ថែម អ្នកផ្តល់ឱវាទ សេវាកម្មសុខភាពផ្លូវចិត្ត ការគាំទ្រដល់គ្រួសារ និងសេវាកម្មសង្គមកិច្ចផ្សេងៗទៀតនៅសាលាវិទ្យាល័យ។